# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ក្នុងព្រះពុទ្ធសាសនាមាននិយាយអំពីព្រះអរហន្តខ្លះ មានឫទ្ធិអាចហោះហើរដើរលើអាកាសបាន តើជាការពិតមែនឬទេ ?

www.hoksavann.org

ថ្ងៃទី២ កក្កដា ២០១២



ឫទ្ធិអស្ចារ្យដែលនិយាយក្នុងព្រះពុទ្ធសាសនាថា មានព្រះអរហន្តអង្គខ្លះមានឫទ្ធិអាចសំដែងអាការៈផ្សេងៗ ហៅថាអភិញ្ញា ឬវិជ្ជា ដូចជាព្រះនាមរបស់ព្រះពុទ្ធមួយបទថា វិជ្ជាចរណសម្បន្នោ ដែលប្រែថា ព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ វិជ្ជា៨ និងចរណៈ១៥ ។ វិជ្ជា៣របស់ព្រះពុទ្ធគឺ បុព្វេនិវាសានុស្សតិញ្ញាណ ព្រះអង្គរឭកជាតិបាន តាំងពី១ជាតិរហូតអសង្ខេយ្យជាតិ គឺមនុស្សសត្វតែងវិលកើត វិលស្លាប់រាប់ជាតិមិនអស់ ។ ចុតូបបាតញ្ញាណ ដឹងចុតនិងបដិសន្ធិនៃមនុស្សសត្វ គឺដឹងបុព្វហេតុដែលនាំឲ្យកើត គឺបណ្ដាលមកពីកម្មរបស់ខ្លួន ។ អាសវក្ខយញ្ញាណ បញ្ញាឃើញអរិយសច្ច៤ ដែលធ្វើឲ្យកិលេសនៃព្រះអង្គអស់ទៅបាន ។ ថែមវិជ្ជា៥ទៀតទៅជា៨គឺ មនោមយិទ្ធិវិជ្ជា ប្រែថាវិជ្ជាអាចធ្វើឫទ្ធិតាមផ្លូវចិត្ត គឺវិជ្ជាអាចនិមិត្តចិត្តខាងក្នុងឲ្យទៅជារូបកាយផ្សេងចេញពីកាយនេះមកប្រាកដ ដូចជាទាញហូតបណ្ដូលស្មៅឃ្លាប្លុងចេញពីដើម ។ ឥទ្ធិវិធីវិជ្ជា ប្រែថាវិជ្ជានេះសំដែងឫទ្ធិបាន គឺវិជ្ជាអាចប្លែង ឬអធិដ្ឋានមនុស្សម្នាក់ឲ្យទៅជាច្រើននាក់បាន ឬច្រើននាក់ឲ្យទៅជាម្នាក់ ឬធ្វើរបស់នេះឲ្យទៅជារបស់នោះ ។ ទិព្វសោតវិជ្ជា គឺវិជ្ជាអាចស្ដាប់សូរសម្លេងមនុស្សនិងទេវតា ដែលត្រចៀកធម្មតាមិនអាចស្ដាប់បាន ។ ទិព្វចក្ខុ ភ្នែកទិព្វ គឺឃើញរបស់ ឬមនុស្ស សត្វ ទេវតា ដែលមើលមិនឃើញដោយភ្នែកធម្មតា ។ ចេតោបរិយវិជ្ជា គឺវិជ្ជាអាចដឹងចិត្តរបស់មនុស្សសត្វបាន ។ វិបស្សនាវិជ្ជា គឺបញ្ញាពិចារណាឃើញជាក់ច្បាស់នូវរូបធម៌និងនាមធម៌ គឺខន្ធ៥ដែលប្រព្រឹត្តទៅដោយលក្ខណៈ៣យ៉ាង គឺអនិច្ចំ ទុក្ខំ អនត្តា ។

វិជ្ជាដែលអាចកើតជាអភិញ្ញា ឬជាឫទ្ធិបាននេះ លុះត្រាតែអប់រំឲ្យបានចិត្តជាន់ខ្ពស់ ជាមហគ្គតចិត្ត គឺជារូបាវចរចិត្ត និងអរូបាវចរចិត្ត ផ្អែកបានឈានជាតួអប្បនាចិត្ត ខ្ពស់ជាងកាមាវចរចិត្ត គឺរម្ងាប់នូវនីវរណៈទាំង៥ មានកាមច្ឆន្ទៈជាដើម ហើយទើបបង្អោនទៅដើម្បីអភិញ្ញា គឺសំដែងឫទ្ធិបានដោយមានអប្បនាចិត្តជាមូលដ្ឋាន ។ ដូច្នេះឫទ្ធិមិនងាយធ្វើឲ្យកើតឡើងណាស់ ។ ព្រះអរហន្តដែលជាសុក្ខវិបស្សកៈ លោកចំរើនវិបស្សនាបានសំរេចមគ្គផលនិព្វាន ពុំដើរតាមឈាននេះទេ ដូច្នេះលោកពុំអាចធ្វើអភិញ្ញា ឬឫទ្ធិនេះឲ្យកើតឡើងឡើយ ។ ដើម្បីមានអភិញ្ញាឬឫទ្ធិនេះ ត្រូវអប់រំចិត្តឲ្យបានតាំងពីឈានទី១ដល់ឈានទី៥ ហើយបង្អោនទៅដើម្បីឫទ្ធិនេះ ដោយផ្សំគ្នានឹងឧបនិស្ស័យមានមកពីមុនផង ។ ក្នុងគម្ពីរវិសុទ្ធិមគ្គបានពោលថា បើត្រូវការបំបាំងខ្លួន ដើរចេញតាមជញ្ជាំង ឬទីមានបិទបាំង ត្រូវចូលអាកាសកសិណ អធិដ្ឋាន របស់បិទបាំងទាំងនោះជាអាកាស របស់ទាំងនោះក៏ក្លាយជាអាកាស អាចចេញចូលបានដោយងាយ ក៏អធិដ្ឋានដីឲ្យទៅជាទឹក ។ បើត្រូវការដើរលើទឹក ឲ្យចូលបឋវីកសិណ ដោយអធិដ្ឋានទឹកឲ្យទៅជាដី អាចដើរឆ្លងស្ទឹងបាន គេមើលហាក់ដូចជាដើរលើទឹក ។ បើចង់ធ្វើដំណើរឲ្យបានលឿន ហាក់ដូចជាហោះហើរដើរលើអាកាស ឲ្យចូលអាកាសកសិណ ដោយអធិដ្ឋានដីឲ្យទៅជាអាកាស ។ ឫទ្ធិទាំងនេះពុំមែនជាផ្លូវត្រាស់ដឹងដើម្បីរំដោះទុក្ខឡើយ ព្រះពុទ្ធនិងព្រះអរហន្តខ្លះមានឫទ្ធិទាំងនេះ ដើម្បីប្រយោជន៍ដល់ការផ្សាយព្រះពុទ្ធសាសនា ដើម្បីដាក់មានៈដល់អ្នកខ្លះដែលមានឫទ្ធិទាំងនេះមិនព្រមស្ដាប់ធម៌ ដោយឃើញឫទ្ធិរបស់ខ្លួនអន់ជាង ទើបព្រមស្ដាប់ធម៌ ។ ឫទ្ធិនេះកើតឡើងដោយរូបាវចរចិត្តសង្កត់នូវនីវរណធម៌ មានកាមច្ឆន្ទ និងព្យាបាទៈជាដើម បើប្រើផ្លូវចិត្តខុស អភិញ្ញា ឬឫទ្ធិ នេះនឹងត្រូវវិនាស ព្រោះវិនាសអប្បណាឈានមុន ដូចភិក្ខុទេវទត្ត ឫទ្ធិត្រូវវិនាសដោយប្រទូស្សរ៉ាយចំពោះព្រះពុទ្ធជាម្ចាស់ ។ ព្រះមោគ្គល្លាននិងព្រះមាល័យត្ថេរ ដែលបានទៅស្ថានសួគ៌និងស្ថាននរក ក៏ប្រើឫទ្ធិទាំងនេះដែរ ។

ដូចបានពោលមកហើយ ឫទ្ធិទាំងនេះពិតជាមាន ដែលមានចែងក្នុងគម្ពីរព្រះត្រៃបិដកនិងគម្ពីរវិសុទ្ធិមគ្គ ហើយឫទ្ធិទាំងនេះ ព្រះមានដោយផ្ទាល់ខ្លួនព្រះអង្គដូចវិជ្ជា៨ប្រការ ។ ហេតុដែលមនុស្សបច្ចុប្បន្ននេះមិនឃើញមានអ្នកណាកើតមាន ទំនងជាការប្រតិបត្តិពុំបានម៉ត់ចត់ ទាក់ទងនឹងឧបនិស្ស័យពីមុនពុំមានគ្រប់គ្រាន់ផង ។ ឈានចិត្តនេះ ជាចិត្តដ៏ខ្ពស់ជាងកាមាវចរចិត្ត ព្រះពុទ្ធមិនបានគិតជាអចិន្តេយ្យំផង ។ ដើម្បីឲ្យដឹងការពិត សូមអ្នកសិក្សាស្រាវជ្រាវកុំបដិសេធ សូមសាកល្បងអនុវត្តពិសោធន៍មើល ព្រោះអាថ៌កំបាំងក្នុងលោកនៅមានច្រើនណាស់ ។៚

*　　*

*